# សម្ភាសន៍ជាមួយឈ្មោះ ខុង ណណ ភេទស្រី អាយុ៤៥ឆ្នាំ

## មុខងាររសម័យខ្មែរក្រហមៈ «កុមារ»

## ស្រុកកំណើតនៅភូមិខ្វាវ ឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប

## រស់នៅភូមិបន្ទាយចាស់ ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ សោម ប៊ុនថន

## ០០:៤០:០៤

## ២២ទំព័រ

ប៊ុនថនៈ ចឹងដំបូងនេះខ្ញុំសុំសម្ភាសអ្នកមីង មីងអនុញ្ញាតឲ្យខ្ញុំសម្ភាសទេ?

ណណៈ ចាស ។

ប៊ុនថនៈ ហើយខ្ញុំកត់ត្រាចូលក្នុងសៀវភៅ តែដោយសារខ្ញុំកត់មិនទាន់ ចឹងខ្ញុំសុំថតជាសម្លេងមីង ។

ណណៈ ចាស ។

ប៊ុនថនៈ ចឹងមីងអនុញ្ញាតឲ្យខ្ញុំទេ?

ណណៈ ចាស ។

ប៊ុនថនៈ ចឹងមីងឈ្មោះអីដែរ?

ណណៈ ឈ្មោះ ខុង ណណ ។

ប៊ុនថនៈ មីងអាយុប៉ុន្មានហើយ?

ណណៈ អាយុ៤៥ ។

ប៊ុនថនៈ មីងមានស្រុកកំណើតនៅភូមិឃុំអីដែរ?

ណណៈ ស្រុកកំណើតនៅភូមិខ្វាវ ឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប ។

ប៊ុនថនៈ បច្ចុប្បន្នមីងនៅភូមិឃុំអីដែរ?

ណណៈ បច្ចុប្បន្ននៅភូមិបន្ទាយចាស់ ។

ប៊ុនថនៈ ឃុំព្រះប្រឡាយ?

ណណៈ ចាស ។

ប៊ុនថនៈ ស្រុកត្រពាំងប្រាសាទ?

ណណៈ ចាស ។

ប៊ុនថនៈ ខេត្តឧត្តរមានជ័យ?

ណណៈ ខេត្តឧត្តរមានជ័យ ។

ប៊ុនថន៖ មីងមានបងប្អូនប៉ុន្មាននាក់?

ណាណៈ ខ្ញុំមានបងប្អូនពីរនាក់ ។

ប៊ុនថន៖ មីងកូនទីប៉ុន្មាន?

ណាណៈ កូនទី១ ។

ប៊ុនថន៖ កូនទី២ឈ្មោះអីដែរ?

ណាណៈ ខ្ញុំភ្លេះ ។

ប៊ុនថន៖ ចឹងមួយទៀតឈ្មោះអី?

ណាណៈ ខុង អ៊ី ។

ប៊ុនថន៖ តែមីងកើតមកមុន?

ណាណៈ ចាស ។

ប៊ុនថន៖ ចឹងឪពុកម្ដាយមាននៅរស់ដែរ?

ណាណៈ ស្លាប់អស់ហើយ ។

ប៊ុនថន៖ ស្លាប់ជំនាន់ណា?

ណាណៈ ពុកខ្ញុំស្លាប់ជំនាន់ លន់ នល់ ។

ប៊ុនថន៖ គាត់ឈ្មោះអីឪពុក?

ណាណៈ ឈ្មោះ ខុង រឹម ។

ប៊ុនថន៖ ចឹងម្ដាយ?

ណាណៈ ម្ដាយឈ្មោះ ហ៊ីប អ៊ុន ។

ប៊ុនថន៖ គាត់នៅរស់ទេ?

ណាណៈ ស្លាប់អស់ហើយ ។

ប៊ុនថន៖ ស្លាប់ជំនាន់ណាដែរ?

ណាណៈ ស្លាប់ជំនាន់នេះឯង ស្លាប់បានបួនឆ្នាំហើយ ។

ប៊ុនថន៖ គាត់ស្លាប់នៅស្រុក?

ណាណៈ ចាស!គាត់ស្លាប់នៅស្រុក នៅខ្វាវនោះ ។

ប៊ុនថន៖ គាត់នៅជាមួយប្អូនស្រី?

ណាណៈ ចាស! នៅជាមួយប្អូនស្រីខ្ញុំ ។

ប៊ុនថន៖ មីងកាលពីតូចរៀនសូត្រដល់ណាដែរ?

ណាណៈ អត់មានបានរៀនទេ ខ្ញុំមកពីអត់ពេក ម៉ែឪខ្ញុំអត់ពេក ឪពុកស្លាប់តាំងពីខ្ញុំទើបចេះអង្គុយ ។

ប៊ុនថន: ចឹងមីងអត់បានរៀនទេ?

ណាណា: អត់បានរៀន ។

ប៊ុនថន: ចឹងឪពុកម្ដាយមីងគាត់ធ្វើអីដែលកាលគាត់នៅរស់?

ណាណា: តាំងពីខ្ញុំដឹងធំមកឪពុកម្ដាយខ្ញុំធ្វើស្រែចម្ការ ។

ប៊ុនថន: ចឹងមីងអត់មានរៀនចឹង មីងនៅធ្វើអីទៅ?

ណាណា: ខ្ញុំអត់រៀនម៉ែខ្ញុំឲ្យទៅឃ្វាលគោ ទៅដើរស៊ីឈ្នួលគេ ។

ប៊ុនថន: ចឹងក្នុងសម័យលន់ នល់ មីងនៅក្នុងភូមិឃុំ?

ណាណា: ចាស! នៅភូមិឃុំខ្វាវហ្នឹងឯង ។

ប៊ុនថន: ចឹងក្រោយមកទៀត?

ណាណា: ក្រោយមក៧៩ខ្ញុំរត់មកនៅក្រៅភូមិ ម៉ែខ្ញុំនាំរត់ ។

ប៊ុនថន: ចឹងឆ្នាំ៧៥-៧៦?

ណាណា: ឆ្នាំ៧៥-៧៦ ខ្ញុំនៅតាមព្រៃ នៅក្នុងព្រៃខ្ញុំរត់នៅក្នុងព្រៃទៅដល់ហើយម៉ែខ្ញុំរត់មកដល់ហើយ ខ្ញុំភ្លេចខ្លះអីខ្លះ ខ្ញុំនៅតូចដែរ ។

ប៊ុនថន: ឆ្នាំ៧៥ខ្មែរក្រហមវាយបានភ្នំពេញ?

ណាណា: ខ្ញុំចូលភូមិវិញ ។

ប៊ុនថន: ចឹងមុនហ្នឹងមីងនៅក្នុងព្រៃ?

ណាណា: ចាស! នៅក្នុងព្រៃ ។

ប៊ុនថន: នៅជាមួយខ្មែរក្រហមរំដោះហ្នឹង?

ណាណា: ចាស! នៅក្នុងព្រៃ ។

ប៊ុនថន: មីងនៅខាងខ្មែរក្រហមគ្រប់គ្រង?

ណាណា: ចាស ។

ប៊ុនថន: មីងមានចូលកងចូលអីទេ?

ណាណា: អត់ស្គាល់កងទេ ខ្ញុំនៅតូចដែរ ។

ប៊ុនថន: មីងមានចូលកុមារអីទេ?

ណាណា: អត់ខ្ញុំនៅតូច ។

ប៊ុនថន: ចឹងនៅជាមួយឪពុកម្ដាយ?

ណាណា: ចាស! នៅតាមម៉ែ ។

ប៊ុនថន: មីងចេញពីភូមិឆ្នាំណា តាំងពីឪពុកស្លាប់?

ណាណៈ ឆ្នាំណាទេ ម៉ែខ្ញុំថា៧៩ ចំណាំតែ៧៩ រត់នោះ ។

ប៊ុនថនៈ ៧៩រត់វៀតណាមចូលហើយ?

ណាណៈ ចាស!ខ្ញុំរត់ហើយខ្ញុំនៅតូចហ្នឹងខ្ញុំនៅភូមិទេ ដល់៧៩យួនចូលមករត់ រត់មកនៅតាមព្រៃ ។

ប៊ុនថនៈ កាលហ្នឹងមីងអាយុប៉ុន្មាន?

ណាណៈ ដឹងថាអាយុប៉ុន្មានទេ អត់ចាំដែរ ។

ប៊ុនថនៈ មីងដឹងក្តីហើយនៅ?

ណាណៈ ដឹងហើយ កុមារគេធ្វើទំនប់ធ្វើអី ។

ប៊ុនថនៈ ចឹងឆ្នាំ១៩៧៥មីងនៅក្នុងភូមិទេ?

ណាណៈ ចាស ។

ប៊ុនថនៈ មីងធ្វើអីនៅក្នុងភូមិពេលខ្មែរក្រហមទទួលជ័យជំនះ?

ណាណៈ មានធ្វើអីទេ នៅផ្ទះដើរជាប់ជាមួយម៉ែ ។

ប៊ុនថនៈ ចឹងម្តាយមីងធ្វើអីដែរ?

ណាណៈ ម្តាយខ្ញុំគាត់នៅខាងដាំបាយដាំអីឲ្យគេហូប ។

ប៊ុនថនៈ ចឹងនៅខាងរោងបាយ?

ណាណៈ ចាស ។

ប៊ុនថនៈ ដាំបាយនៅក្នុងភូមិ?

ណាណៈ នៅក្នុងភូមិឃុំដដែលហ្នឹងហើយ តែគាត់នៅដាំបាយ កាលហ្នឹងខ្ញុំបានបាយក្តាំងហូប ខ្ញុំក្មេចខ្លះ អីខ្លះហើយខ្ញុំនៅតូចពេក ។

ប៊ុនថនៈ មីងហូបឆ្អែតទេ?

ណាណៈ ហូបមិនឆ្អែតទេ កាលជំនាន់នោះ តែយើងលួចហូបខ្លះបាយក្តាំងអីចេះតែហូបទៅ ។

ប៊ុនថនៈ នៅខាងរោងបាយមានរបបបាយដែលទេ?

ណាណៈ មានតែគេចែក ម្នាក់មួយចានៗ បាយលាយពោត លាយដំឡូង លាយអីឲ្យហូបហ្នឹងណាស់ កាលហ្នឹង ។

ប៊ុនថនៈ ចឹងមីងសម្រាកនៅជាមួយម្តាយ?

ណាណៈ ចាស!ជាមួយម៉ែ ដល់ពេលម៉ែខ្ញុំគេចល័តនៅឆ្ងាយទៅ គេឲ្យនៅជាមួយយាយចាស់ យាយខ្ញុំចាស់ហើយអាយុ៨០ជាងហើយ ។

ប៊ុនថនៈ គាត់ចល័តនៅណាខ្លះ?

ណាណៈ ចាស!គេយកទៅឲ្យដាំបាយឲ្យអ្នកលើកទំនប់អី ។

ប៊ុនថន: ចឹងពេលគាត់ទៅធ្វើការចឹង មីងអត់មានទៅតាមគាត់ទេ?

ណាណេ: គេអត់ឲ្យទៅទេ ឲ្យនៅផ្ទះហ្នឹង យើងដើរទៅសាលាចឹងឲ្យរៀនចឹងឯងទៅកាត់ដីដាក់ឲ្យគេ ។

ប៊ុនថន: គេឲ្យទៅរៀនអីគេ?

ណាណេ: គេឲ្យទៅរៀនសាលាដែរ ដឹងថាឲ្យទៅរៀន រៀនអត់មានដឹងណាណីទេ ចេះតែទៅហ្នឹងគេទៅកាលហ្នឹង ។

ប៊ុនថន: រៀនពីអីវិញ?

ណាណេ: រៀនអក្សរយើងធម្មតាហ្នឹងឯង តែអត់ដឹងគេទៅរៀនហើយគេឲ្យកាប់ដីដើម ចាំបានត្រឹមកាប់ដើមកន្ទ្រាំងខែត្រច្រើនជាងគេ ។

ប៊ុនថន: កាប់យកទៅណាវិញ?

ណាណេ: យកទៅធ្វើជីដាក់ក្នុងរណ្ដៅអីណា សិស្សសាលានៅតូចៗ ។

ប៊ុនថន: ខាងណាគេឲ្យកាប់មីង?

ណាណេ: ខាងលោកគ្រូអីហ្នឹង លោកគ្រូនៅសាលាហ្នឹង ។

ប៊ុនថន: លោកគ្រូក្មេងៗឬមនុស្សចាស់?

ណាណេ: លោកគ្រូធំដែលហើយឲ្យទៅរៀន ។

ប៊ុនថន: បង្រៀនក្នុងមួយថ្ងៃប៉ុន្មានម៉ោង?

ណាណេ: រៀនបានតែពេលព្រឹកៗ ។

ប៊ុនថន: ពេលព្រឹកមានប៉ុន្មានម៉ោង?

ណាណេ: ពេលព្រឹកពីម៉ោង៧រហូតដល់ម៉ោង១១ឲ្យមកផ្ទះ តែរៀនមិនដឹងអីទេ ចេះតែរៀនទៅ ។

ប៊ុនថន: រៀនបានយូរទេ?

ណាណេ: រៀនបានបន្តិចក៏បែកគ្នាគេឈប់ឲ្យរៀនមានយន្តហោះបាញ់ណារត់បែកផ្លូវគ្នា ព្រោងព្រាតអស់ទៅ ។

ប៊ុនថន: រៀនបានប៉ុន្មានឆ្នាំមីង?

ណាណេ: រៀនមិនបានប៉ុន្មានទេ ខ្ញុំចាំបានត្រង់ថា រៀនបានតិចកំពង់រៀនស្រាប់តែមានយន្តហោះបាញ់ក៏រត់បែកគ្នាព្រោងព្រាតអស់ទៅ ។

ប៊ុនថន: រត់ទៅខាងណាវិញ?

ណាណេ: រត់ពីសាលាចូលមកក្នុងភូមិវិញ ។

ប៊ុនថន: សាលានៅជិតភូមិ?

ណាណេ: សាលាឆ្ងាយដែលប្រហែលជា២០០ម៉ែត្រអីយ៉ាង ពីភូមិហ្នឹង ។

ប៊ុនថន: សាលាក្នុងភូមិ?

ណាណេ: ចាស ។

ប៊ុនថន: រត់មកដល់ភូមិហើយមានរឿងយ៉ាងម៉េចទៀត?

ណាណេ: រត់មកដល់ភូមិហើយជួបយាយ បើម៉ែអត់ជួបទេ ម៉ែដល់ពេលយន្តហោះឈប់បាញ់បានម៉ែមកជួប ។

ប៊ុនថន: គាត់មកជួបហើយមីងនៅក្នុងភូមិដដែល?

ណាណេ: ចាស! នៅក្នុងភូមិហ្នឹងដដែល នៅក្នុងភូមិរហូតដល់ពេលនេះនៅក្នុងភូមិអត់មាននេះ យន្តហោះនៅខ្លាចចូលត្រង់សេទេខ្លាច ខ្លាចយន្តហោះបាញ់ កាលហ្នឹងមានយន្តហោះមកបាញ់ មិនដឹងជាជំនាន់ណាខ្ញុំមិនសូវចាំដែរ ។

ប៊ុនថន: មីងនៅក្នុងត្រង់សេហ្នឹងយូរទេ?

ណាណេ: នៅយូរលោកគ្រូ នៅរាប់ខែណា បានគេឈប់បាញ់ ។

ប៊ុនថន: អត់ដឹងឆ្នាំទេ?

ណាណេ: អត់ដឹងខែឆ្នាំទេ យាយចាស់ហើយខ្លាចចៅរត់មិនរួចឲ្យចៅដេកតែក្នុងត្រង់សេទេ អត់ឲ្យចេញទេ ពេលយប់ហូបបាយហើយចូល ។

ប៊ុនថន: ចឹងថ្ងៃឡើងចេញដើរ?

ណាណេ: ថ្ងៃឡើងយើងចេញដើរបាន ដងទឹកអីទៅកិនបុកស្រូវអីហ្នឹង ដល់ពេលយប់ឡើងដេកត្រង់សេមិនដែលហ៊ានដេកចេញក្រៅទេ តាថាអត់មានពីណាយក យាយតាខ្ញុំចាស់ៗហើយអត់មានពីណាយក ខ្ញុំដេកតែក្នុងហ្នឹងរហូត ទាល់គេថាអត់អីទេ លែងមានអីហើយ ចុងក្រោយមកដេកក្រោមផ្ទះម្តង ឈប់ដេកក្នុងត្រង់សេហើយ ។

ប៊ុនថន: មីងនៅសៀមរាបដល់ពេលណាបានមីងចេញមកហ្នឹង?

ណាណេ: ដល់ឆ្នាំ៨៧ ខ្ញុំធំដឹងឆ្នាំ៨៧ ខ្ញុំរកស៊ីលក់ប្រហុកលក់ត្រីឆ្អើរ ហើយបានជួបទ័ពយើងខ្មែរក្រហមហ្នឹងឯង លក់ៗយូរៗទៅក៏គេចាប់ គេចាប់ទៅខ្ញុំរត់រួចមួយសារ ។

ប៊ុនថន: ខាងណាចាប់មីង?

ណាណេ: ខាងទ័ពខាងក្នុងហ្នឹងចាប់ ចាប់មិនឲ្យយើងលក់ទេ គេថាយើងលក់ឲ្យប៉ុល ពត ថាចឹង ដល់អត់ពេកលួចលក់ម្តងទៀត ចុះអត់មានពីណារកចិញ្ចឹមណា រកខ្លួនឯង ធំដឹងក្តីឡើងរកខ្លួនឯងដើរស៊ីឈ្នួលគេ បានបន្តិចៗមកចិញ្ចឹមប្អូនពីរនាក់ ពីរនាក់បងប្អូននិងឯង ដើរស៊ីឈ្នួលគេហើយម៉ែទៅបាត់ៗនៅជាមួយយាយចាស់ ។

ប៊ុនថន: ម្តាយគាត់ទៅណា?

ណាណេះ   ម៉ែខ្ញុំដើរទៅរកស៊ីឈ្នួលគេឆ្ងាយៗចឹងណា បើខែវស្សាដើរធ្វើស្រែនិងគេ ។

ប៊ុនថនៈ   ចឹងមីងនៅខាងទ័ពខាងក្នុងទេ ជាអ្នកគ្រប់គ្រង?

ណាណេះ   នៅទ័ពខាងក្នុងរហូតដល់ពេលខ្ញុំលក់យូរៗទៅបែកទៅ បានម៉ែខ្ញុំឲ្យរត់ចេញមកនៅខាងក្រៅវិញ គេរកចាប់ពេក គេរកចាប់ទៅ គេចាប់ម៉ែខ្ញុំទៅបាត់ទៅ ខ្ញុំរត់ទៅក្រៅ ។

ប៊ុនថនៈ   ខាងហ្នឹងចាប់នៅណា?

ណាណេះ   ចាប់ម៉ែខ្ញុំទៅឃុំពីរថ្ងៃ គេថាឲ្យរកកូនឲ្យឃើញ ចុះបាត់ខ្ញុំ គេចាប់ថាឲ្យរកកូនឲ្យមកផ្ទះវិញមក គេអត់ចាប់ទេ គេឈប់ចាប់ហើយ ដល់ហើយខ្ញុំមិនហ៊ានទៅវិញទេ ខ្ញុំខ្លាចគេចាប់ដូចម៉ែខ្ញុំទៀត ចុះយើងនៅក្មេងផង ។

ប៊ុនថនៈ   បាទ ។

ណាណេះ   ខ្ញុំរត់មកតាមគេទៅ ។

ប៊ុនថនៈ   មីងរត់មកតាមពីណា?

ណាណេះ   រត់មកតាមទ័ពខ្មែរក្រហមយើង ។

ប៊ុនថនៈ   កាលហ្នឹងលក់ឲ្យហ្នឹងលក់ឲ្យខាងណាវិញ?

ណាណេះ   លក់ឲ្យខាងខ្មែរក្រហម ។

ប៊ុនថនៈ   តែនៅស្រុកណាវិញ?

ណាណេះ   នៅក្នុងភូមិខ្វាវហ្នឹងឯង លួចមកលក់ក្នុងព្រៃ ។

ប៊ុនថនៈ   ជិះពីផ្ទះមកយកមកលក់ក្នុងព្រៃ?

ណាណេះ   ចាស ។

ប៊ុនថនៈ   ចឹងដោះដូរជាមួយខ្មែរក្រហមហ្នឹងជាអីជាលុយ?

ណាណេះ   ជាលុយផងជាក្រណាត់ជាសារុងជាក្រមាអីហ្នឹង ស្រេចតែគេឲ្យ ។

ប៊ុនថនៈ   ចឹងលុយហ្នឹងលុយអីវិញ?

ណាណេះ   លុយពីខ្មែរយើងហ្នឹង ។

ប៊ុនថនៈ   លុយដែលខាងក្នុងគេចាយហ្នឹង?

ណាណេះ   ចាស!លុយបាតគេឲ្យដែលអត់យកយើងអត់ស្គាល់ ដល់ហើយគេរកចាប់ខ្ញុំរត់មួយសារទៀត ខ្ញុំអត់ទៅវិញ ទេ ។

ប៊ុនថនៈ   ចឹងម្ដាយឆ្នាំ៨៧ដែរ?

ណាណេះ   ចាស ។

ប៊ុនថនៈ   ចាប់ម្ដាយហ្នឹងគេចោទថាយ៉ាងម៉េច?

ណាណៈ   គេថាយើងលក់អង្ករឲ្យពួក ប៉ុល ពត គេថាពួកប៉ុល ពត ក្បត់គេថាចិនគេមិនឲ្យយើងលក់ទេ គេថាចិន ។

ប៊ុនថនៈ   ចឹងដឹបូងមីងនៅជាមួយពីណា?

ណាណៈ   ខ្ញុំនៅជាមួយយាយខ្ញុំចាស់ហើយ រហូតដល់ម៉ែខ្ញុំគេឃុំពីរថ្ងៃដល់ហើយគេលែងវិញទៅ គេឲ្យម៉ែខ្ញុំមកយកវិញដែរ តែខ្ញុំថាម៉ែអើយខ្ញុំអត់ទៅវិញទេ ម៉ែចាស់ហើយគេចាប់ទៅ ចុះបើក្មេងគេចាប់ទៅគេធ្វើបាបដែលហើយ ខ្ញុំសម្រេចចិត្តថាខ្ញុំមកនេះ ខ្ញុំសម្រេចចិត្តមកក៏មកតស៊ូជាមួយខាងទ័ពខ្មែរក្រហមរហូតដល់ឥឡូវ តាំងពីឆ្នាំ៨៧ដល់បច្ចុប្បន្នឥឡូវហ្នឹង ។

ប៊ុនថនៈ   កាលមកដឹបូងមានអ្នកស្គាល់ទេ?

ណាណៈ   អត់ទេ អត់មានអ្នកស្គាល់ទេ មកមានបងស្រីម្នាក់មកពីខាងខេត្តកំពង់ឆ្នាំង គាត់យកប្ដីគាត់មកតាមផ្លូវសុំស្គាល់គាត់ទៅ រាប់អានគាត់មកតាមគាត់មករហូត ។

ប៊ុនថនៈ   ចឹងគាត់ចេញពីក្នុងមកដែរ?

ណាណៈ   ចាស!គាត់មកពីក្នុងដែរ ។

ប៊ុនថនៈ   ចឹងកាលមីងចេញមកម្នាក់ឯង?

ណាណៈ   មកម្នាក់ឯង ។

ប៊ុនថនៈ   មកពេលយប់ឬពេលថ្ងៃ?

ណាណៈ   មកពេលយប់ ។

ប៊ុនថនៈ   រត់ទៅខាងណាវិញ?

ណាណៈ   ចេញមកដើងត្រង់បានចូលព្រៃ ដើរកាត់វាលស្រែបានចូលព្រៃជាប់តាមផ្លូវដែលខ្ញុំធ្លាប់លក់ ខ្ញុំចំណាំកន្លែងកង់ខ្ញុំធ្លាប់ជិះមក ដល់ហើយគេហៅយើងចូល ដល់ហើយគេសួរនាំចេះចុះក៏គេឲ្យខ្ញុំនៅជាមួយ មួយរយៈសិនទៅ ។

ប៊ុនថនៈ   ចូលជាមួយកងទ័ព?

ណាណៈ   ចាស!ចូលជាមួយកងទ័ពហ្នឹងទៅ ។

ប៊ុនថនៈ   ចឹងមីងអត់ខ្លាចទេ ពេលដើរមកម្នាក់ឯង?

ណាណៈ   អត់ខ្លាចទេ មកជាមួយបងៗពូៗហ្នឹងគាត់ស្មោះត្រង់ដែលហ្នឹង គាត់មានធ្វើបាបអីផងហ្នឹង ។

ប៊ុនថនៈ   មកជួបគ្នាក្នុងព្រៃតែម្ដង?

ណាណៈ   ចាសៗ!មកជួបគ្នាក្នុងព្រៃយប់បណ្ដោយ គេបាញ់ខ្ញុំដែលម៉ោង៨ទៅ៩យប់ គេជិតបាញ់ខ្ញុំដែលដល់ពេលគេចុចពិលទៅគេឃើញមនុស្សស្រី ដល់ហើយគេអត់បាញ់គេថា បិសគេបាញ់

ហើយតើ គេសួរថា ប្រុសស្រី ដល់ហើយឆ្លើយថាស្រី គេឈ្លួលពិលមើលទៅដល់ហើយគេថាមនុស្សស្រីទេ បានគេអត់បាញ់ទៅ ។

ប៊ុនថន៖ ចឹងបន្តមកទៀត?

ណាណា៖ ដល់ហើយបន្ទាប់មកគេបញ្ជូនខ្ញុំឡើងភ្នំចឹង គេនាំខ្ញុំឡើងភ្នំមកទៅនៅជាប់ស្រុកថៃតាមព្រំដែនហ្នឹង ព្រំដែនថៃហ្នឹង ។

ប៊ុនថន៖ មកខាងណាវិញ?

ណាណា៖ មកឡើងច្រក៥០ហ្នឹង ។

ប៊ុនថន៖ ជណើរ៥០?

ណាណា៖ ចាស! ច្រកជណ្តើរ៥០ ។

ប៊ុនថន៖ បច្ចុប្បន្ននៅក្នុងភូមិឃុំអីដែរ?

ណាណា៖ ជណ្តើរ៥០នៅច្រកខាងអន្លង់វែងហ្នឹង ។

ប៊ុនថន៖ ច្រកជាំ?

ណាណា៖ ខាងនេះ ។

ប៊ុនថន៖ ចឹងអានសេះនៅខាងណា?

ណាណា៖ អានសេះនៅខាងនេះទេ នៅច្រកជណ្តើរ៥០នៅច្រក ចំណាំគេហៅជណ្តើរ៥០ហ្នឹងឯង ។

ប៊ុនថន៖ ចឹងឥឡូវនៅក្នុងទឹកដីស្រុកអន្លង់វែង?

ណាណា៖ ចាស! នៅក្នុងទឹកដីស្រុកអន្លង់វែងនេះឯង ។

ប៊ុនថន៖ ចឹងទ័ពមកហ្នឹង?

ណាណា៖ ចាស! ទ័ពឡើងមកពីខាងបូព៌ា ឡើងមកពីក្នុងមក ឡើងមកពីទន្លេមក ឡើងមកពីទន្លេមកខ្ញុំលក់ឥវ៉ាន់ឲ្យគេ មិនបានយូរទេ លក់ប្រហែលជាកន្លះខែហ្នឹង បែកការណ៍ បែកការណ៍ហើយខ្ញុំមកតាមគេទៅ ខ្ញុំសួរទ័ពមកពីខាងណា គេថាមកពីបូព៌ា មកពីខាងទន្លេ ។

ប៊ុនថន៖ តែទ័ពហ្នឹងនៅកងប៉ុន្មាន?

ណាណា៖ គេចំណាំថា៦១២ ។

ប៊ុនថន៖ មាននៅចាំឈ្មោះគាត់ទេ អ្នកដែលនាំមីងមក?

ណាណា៖ ចាំតើ ។

ប៊ុនថន៖ គាត់ឈ្មោះអី?

ណាណា៖ ឈ្មោះ បងឈន ។

ប៊ុនថន៖ ឈន ហ្នឹងកាលហ្នឹងគាត់ធ្វើអី?

ណាណោះ  គាត់នៅវរសេនាធំ ។

ប៊ុនថន:  វរសេនាធំលេខប៉ុន្មាន?

ណាណោះ  អត់ស្គាល់លេខទេ ។

ប៊ុនថន:  ចឹងមានពីណាទៀត?

ណាណោះ  ហើយមកជាមួយបងរិទ្ធ ។

ប៊ុនថន:  បងរិទ្ធ ហ្នឹងគាត់នៅរស់ទេ?

ណាណោះ  នៅតើ បងរិទ្ធ គាត់រស់នៅទំនប់ដាច់ ហើយបងឈន គាត់នៅទឹកថ្លានោះ ។

ប៊ុនថន:  អត់ស្គាល់ត្រកូលគាត់ទេ?

ណាណោះ  អត់ស្គាល់ ស្គាល់តែឈ្មោះគាត់ ។

ប៊ុនថន:  ចេញពីភូមិមីងមកដល់ច្រកជណ្តើរ៥០ហ្នឹងរយៈពេលប៉ុន្មានថ្ងៃ?

ណាណោះ  យូរណាស់ដើរឡើងកន្លះខែ ចុះដើរស្មើជើង ដើរមកបន្តិចៗគ្រាន់ឆ្លងកាត់ព្រៃស្អាកនេះឡើង វង្វេងផ្លូវ អត់មានទឹកដាច់ទឹកដាច់បាយ ។

ប៊ុនថន:  ច្រើនគ្នាដេលមកហ្នឹង?

ណាណោះ  ច្រើន មានរាប់រយនាក់មកហ្នឹង ។

ប៊ុនថន:  មានស្រីមានប្រុស?

ណាណោះ  មានស្រីមានប្រុស តែមកមិនជួបគេវាយតាមផ្លូវ អត់មានផង បេះអត់មានជួបរហូតបាន សុខរហូតបានឡើងដល់លើភ្នំហ្នឹងឯង វង្វេងព្រៃដើរទៅមកនៅក្នុងព្រៃហ្នឹងដដែល ទំរាំបានផុះ ព្រៃស្អាកហ្នឹង បានមកដល់ជណ្តើរ៥០ គេថាមកដល់ភ្នំហើយ បានគេនាំឡើងជណ្តើរ ឡើង ជណ្តើរខ្ញុំញ័រខ្ញុំខ្លាចជណ្តើរ៥០ងាកមកក្រោមឃើញតែថ្មជ្រៅ ឡើងភ្នំនេះ ខ្ញុំខ្លាចភ័យឡើង ញ័រអស់ហើយ តែធ្វើម៉េចទេ តាមពួៗទៅផ្សងព្រេងទៅ ។

ប៊ុនថន:  បាទ ។

ណាណោះ  ដល់ពេលចឹងទៅខ្ញុំដើរតាមគាត់ គាត់យកទៅឲ្យនៅ បងឈន ហ្នឹងប្រពន្ធគាត់នៅលើភ្នំហ្នឹង ឯង គាត់យកទៅឲ្យនៅជាមួយប្រពន្ធគាត់ ។

ប៊ុនថន:  នៅលើកំពូលភ្នំឬនៅម្ខាងទៀត?

ណាណោះ  នៅលើភ្នំណា ឡើងទៅនៅលើភ្នំជាប់ព្រំដែនថៃ ។

ប៊ុនថន:  ចឹងមិនមែនទឹកដីថៃទេ?

ណាណោះ  ទឹកដីថៃ តែយើងនៅទឹកដីថៃហ្នឹង យើងនៅទឹកបែកមកខាងនេះទឹកដីខ្មែរយើងខាងនេះទឹកបែក ខាងដីថៃ ។

ប៊ុនថនៈ ចឹងមីងនៅទឹកចែកទៅខាងថៃ?

ណាណៈ ចាស!គេឲ្យបោះជំរំឲ្យនៅក្នុងហ្នឹង គេចែកអង្ករអីឲ្យហូប គេយកទៅដាក់ជំរំគេជីកអុសឲ្យយើងដុតគេជីកទឹកអីទៀតនោះ គេមិនឲ្យយើងដើរចេញក្រៅទេ គេបើកអង្ករឲ្យហូបដែរ ។

ប៊ុនថនៈ ចឹងមានត្រីសាច់អីទេ?

ណាណៈ អត់មានទេ មានអង្ករប្រហុក ខ្ទាច ត្រីខ ត្រីមានតែត្រីកំប៉ុងហ្នឹងឯងឲ្យយើងហូប ។

ប៊ុនថនៈ មានប៊ីចេងទេ?

ណាណៈ មានគេឲ្យ ។

ប៊ុនថនៈ ចឹងយើងអាចរកក្រៅហូបបានទេ?

ណាណៈ អត់ទេ ដូចថាថៃបើកមួយសប្តាហ៍ចឹង គេឲ្យថៃហ្នឹងលក់ក្នុងភូមិខ្មែរហ្នឹងម្តងចឹងទៅ តែយើងមានតែអង្ករហ្នឹងឯងដូចជាមួយម្ហូប ។

ប៊ុនថនៈ អត់មានលុយទេ?

ណាណៈ អត់ទេ ។

ប៊ុនថនៈ គេដូរយកអង្ករដែរ?

ណាណៈ យក! យកអង្ករបីបួនប្រាំកំប៉ុងទៅ គេថាថៃបើកហើយយកអង្ករទៅគេមានច្រើនគេយកច្រើនទៅ គេមានតិចយកតិចទៅ ថៃគេបើកឲ្យប្រជាជនគេមិនលក់ ចូលមកលក់មួយសប្តាហ៍ហ្នឹងមានម្តងឬមួយពីរដងប៉ុនហ្នឹងឯង ។

ប៊ុនថនៈ លក់ហ្នឹងមានអីខ្លះ?

ណាណៈ មានត្រីកាម៉ុង មានខ្ទឹមមានខ្សៀងហ្នឹងឯងយកមកលក់ឲ្យយើង បើសាច់អីអត់មានដែលមានទេ ដល់ពេលនេះមកយើងចូលទៅថៃអី បើថៃចិត្តល្អវាឲ្យមាន់អីមកឲ្យយើងចិញ្ចឹមអីទៅណា ។

ប៊ុនថនៈ បាទ!មីងនៅជំរំហ្នឹងគេហៅជំរំអីវិញ?

ណាណៈ ខ្ញុំនៅជំរំដាំស្វា ជំរំអូរត្រាវ ។

ប៊ុនថនៈ ឡើងទៅលើកំពូលភ្នំហ្នឹងគេហៅដាំស្វា?

ណាណៈ ចាស!ដាំស្វា ។

ប៊ុនថនៈ ដាំស្វា អាហ្នឹងនៅក្នុង១០០៣ឬ១០០២?

ណាណៈ អត់ទេ ១០០៣នៅខាងអូរត្រាវ ។

ប៊ុនថនៈ ចឹងដាំស្វាហ្នឹងហៅអីវិញ?

ណាណៈ ដាំស្វាគេហៅច្រកដាំស្វា ដុបរុនហ្នឹងបណ្តោយ ។

ប៊ុនថនៈ ដុបរុន?

ណាណៈ ចាស!ឡើងពីជុំបរុនទៅបានឡើងជាំស្វា ។

ប៊ុនថន: ចឹងមឹងនៅជាំស្វា?

ណាណៈ ចាស ។

ប៊ុនថនៈ នៅហ្នឹងបានរយៈពេលប៉ុន្មាននៅជាំស្វាហ្នឹង?

ណាណៈ នៅយូរតាំងពី៨៧រហូតដល់៩០ ឆ្នាំ១៩៩០បានចុះ គេឲ្យយើងចុះមកក្រោមវិញ ។

ប៊ុនថនៈ ចឹងអ្នកគ្រប់គ្រងនៅជាំស្វាហ្នឹងឲ្យចុះមក?

ណាណៈ ចាស ។

ប៊ុនថនៈ ពីណាអ្នកគ្រប់គ្រងនៅហ្នឹង?

ណាណៈ អ៊ឹហឿន ។

ប៊ុនថនៈ អ៊ុន ហឿន ហ្នឹង?

ណាណៈ ចាស!នៅជាមួយអ៊ឹហឿន ហ្នឹងឯង ។

ប៊ុនថនៈ ចឹងអ៊ឹហឿន គាត់គ្រប់គ្រងនៅជាំស្វាហ្នឹង?

ណាណៈ ចាស!គាត់អ្នកគ្រប់គ្រងទាំងទ័ពអីទាំងអស់ នៅទ័ពជងនៅខាងមឹងៗហ្នឹង នៅខាងតាៗចាស់ៗ ហ្នឹងឲ្យមើលមឹងៗ មើលសភាពការណ៍មិនស្រួលនាំគ្នារត់ មើលសភាពការណ៍មិនស្រួលគាត់ ឲ្យដំណឹងទៅនាំគ្នារត់ ។

ប៊ុនថនៈ រត់ទៅណាវិញ រត់ទៅថៃឬរត់ទៅខាងវិញ?

ណាណៈ ទេ បើសិន កាលនៅជាំស្វាអត់មានរត់ទៅថៃទេ ខ្ញុំនៅហ្នឹងជាប់រហូតតាំងពី៨៧មករហូតទាល់ ឆ្នាំ៩០បានគេឲ្យយើងចុះមកក្រោមវិញ ។

ប៊ុនថនៈ ចុះមកក្រោមចុះមកនៅម្តុំណាមឹង?

ណាណៈ មកនៅប្រកជុំបរុនយើងនេះ ក្រោមដីរាបយើង ជើងភ្នំ ។

ប៊ុនថនៈ នៅកន្លែងបន្ទាយទាហានរាល់ថ្ងៃហ្នឹង?

ណាណៈ ចាស!នៅកន្លែងបន្ទាយទាហានហ្នឹងហើយ ដុះពួកខ្ញុំហ្នឹងនៅតាមបន្ទាយទាហានហ្នឹង ។

ប៊ុនថនៈ នៅជុំបរុនហ្នឹងរបបគេបើកឲ្យយ៉ាងម៉េចដែរ?

ណាណៈ បើកឲ្យតែបើកឲ្យរៀងដាច់ គេផ្តាច់គេថាឲ្យយើងធ្វើស្រែខ្លួនយើង ដល់ហើយពួកខ្ញុំចេះគាត់ និងចបខ្លួនឯង ចេះតែធ្វើលិចកើត ថៃគេឲ្យស្រូវដំណើបបន្តិចៗម្នាក់ដាំទៅបានហូបខ្វះទៅ ។

ប៊ុនថនៈ ចឹងមឹងជួបគ្រួសារនៅហ្នឹងដែរ នៅលើភ្នំដែរ?

ណាណៈ ចាស!ជួបគ្រួសារនៅលើភ្នំហ្នឹងទាំងអស់ ។

ប៊ុនថនៈ ឆ្នាំណាមឹង?

ណាណៈ ឆ្នាំ៨៧ហ្នឹង ។

ប៊ុនថន: ចឹងឆ្នាំ៨៧បានគ្រួសារហើយបានចុះមកក្រោម?

ណាណៈ ចាស!បានគ្រួសារបានកូនមួយហើយបានចុះមកក្រោម បានចុះមកក្រោមទៅបានមួយឆ្នាំទៅ កូនស្លាប់ទៅឈឺពេក កូនក្មេងស្លាប់ច្រើនណាស់ អត់មានពេទ្យអីមើលទាន់ទេ ឈឺពីរបីថ្ងៃ ស្លាប់ៗ ។

ប៊ុនថន: ស្លាប់ដោយសារអីចឹង?

ណាណៈ ស្លាប់ដោយសារអត់ទឹកហូបតែទឹកហូរតាមអូរតាមស្រែ ក្រឡិចក្រឡុកហ្នឹង ។

ប៊ុនថន: ចឹងមានពេទ្យទេ?

ណាណៈ មានតែមើលមិនទាន់ ទៅពេទ្យក៏ស្លាប់ ស្លាប់ព្រឹកស្លាប់ល្ងាច ខ្ញុំអស់កូនមួយកូនពីរ ។

ប៊ុនថន: ចឹងចង់សួរថាមីងរៀបជាមួយគ្រួសារមីងហ្នឹង ស្គាល់គ្នាពីមុនមកឬមួយអត់ទេ?

ណាណៈ អត់ដែលស្គាល់ទេ ពេលខ្ញុំឡើងមកដល់លើភ្នំទៅ ពីដើមដឹបូងខ្ញុំឈឺអត់មានពីណាមើល គាត់មានម៉ែចាស់ម្នាក់ ពឹងគាត់ហ្នឹងឯង ដល់ហើយម៉ែចាស់ហ្នឹងឃើញខ្ញុំអាណិតគាត់ យកខ្ញុំទៅមើល យកខ្ញុំទៅមើលទៅដល់ហើយមានគេដណ្ដឹងក្រៅ គេសួរក្រៅកងទ័ពក្រៅសួរបងឈន ខ្ញុំហ្នឹងឲ្យយកក្រៅទេ អត់ឲ្យយកប្ដីខ្ញុំសព្វថ្ងៃនេះទេ តែខ្ញុំចិត្តមិនដាច់ទេ គេមើលខ្ញុំជាខ្ញុំមិនទៅយកគេទេ ទោះបងឲ្យយកក៏ខ្ញុំមិនយកដែរ ចឹងបងខ្ញុំក៏ខឹងខ្ញុំ គាត់ខំយកពីក្នុងទៅហើយមិនតាមគាត់ថាចឹង ។

ប៊ុនថន: តាឈន ហ្នឹង?

ណាណៈ ចាស!គាត់ខឹងខ្ញុំ ខ្ញុំថាទោះបីបងខឹងក៏ខ្ញុំទៅយកគេដែរ ព្រោះខ្ញុំអាណិតគេ គេមើលខ្ញុំជាហើយកាលហ្នឹង ។

ប៊ុនថន: ចឹងបងឈន ហ្នឹងគាត់ចង់រៀបឲ្យជាមួយពីណាវិញ?

ណាណៈ រៀបឲ្យកូនទាហានគាត់ហ្នឹងឯង ។

ប៊ុនថន: ចឹងពូគាត់ធ្វើទាហានដែរ?

ណាណៈ ធ្វើទាហានដែរ តែទាហានមកពីខាងលើ គាត់មិនមែនកងទ័ពមកពីក្នុងណា ហើយបងឈនខ្ញុំចង់ឲ្យយកកូនទាហានគាត់ទៅក្នុងទាំងអស់គ្នា ។

ប៊ុនថន: គាត់នៅកងណា គ្រួសារមីង?

ណាណៈ គ្រួសារខ្ញុំហ្នឹងនៅកងអឹហឿន ហ្នឹង ។

ប៊ុនថន: ចឹងអឹហឿន ដូចគ្នាតែគាត់នៅខាងលើ?

ណាណៈ ចាស!នៅខាងលើ ។

ប៉ុនថនៈ ចឹងក្រកែកជាមួយគាត់ គាត់មិនថាអីដែរ?

ណាណៈ គាត់មានថាអី គាត់ថាបើយកក៏យកទៅ បើយកមិនឲ្យនៅផ្ទះគាត់ទេ ខ្ញុំថាបើបងមិនឲ្យនៅខ្ញុំនៅជាមួយប្ដីខ្ញុំហើយ គាត់ថាម៉េចបានហៅគេប្ដី ខ្ញុំថាចុះបើគាត់មើលខ្ញុំឡើងជាហើយខ្ញុំឈឺឡើងស្គមគ្រុនចាញ់ ហើយយើងនៅក្មេងខ្ញុំដងមិនដឹងអី សុខចិត្តថាតាមម៉ែ តែម៉ែក្មេងខ្ញុំស្លាប់ហើយ គាត់ស្លាប់នៅចុះមកនៅខាងក្រោមមិនទាន់បានធ្វើបុណ្យទេ ស្លាប់បានបួនឆ្នាំដែរ ម៉ែខ្ញុំមើលថែខ្ញុំល្អណាស់ ដាងម៉ែខ្ញុំបង្កើតទៀត ចិត្តបានណាស់ ។

ប៉ុនថនៈ គាត់អ្នកស្រុកណាដែរ?

ណាណៈ គាត់អ្នកស្រុកកំពង់ធំ ។

ប៉ុនថនៈ ចឹងពូកំពង់ធំដែរ?

ណាណៈ ចាស ។

ប៉ុនថនៈ នៅស្រុកណា?

ណាណៈ នៅភូមិគាត់នៅស្រើង ។

ប៉ុនថនៈ នៅខាងស្រើង?

ណាណៈ ចាស ។

ប៉ុនថនៈ នៅស្រុកអីវិញ?

ណាណៈ នៅស្រុកប្រាសាទសម្បូរ ។

ប៉ុនថនៈ ចឹងពេលរៀបឲ្យហ្នឹងមានដឹងដល់ប្រធានអំហៀន អីទេ?

ណាណៈ ដឹងតើ គាត់ឲ្យអង្ករគាត់ឲ្យត្រីខអី ឲ្យអង្ករយកទៅរៀនអីដែលណា ប្រពន្ធគាត់អ្នករៀបឲ្យ ។

ប៉ុនថនៈ មានធ្វើអីខ្លះមីងពេលហ្នឹង?

ណាណៈ មានធ្វើអីទេ មានតែទិញកន្ទាលថៃមករៀបតែមួយព្រឹកហ្នឹងឯង ។

ប៉ុនថនៈ ហៅភ្ញៀវមកដែរ?

ណាណៈ ចាស! ហៅភ្ញៀវទៅ ។

ប៉ុនថនៈ មានប៉ុន្មាននាក់ទៅ?

ណាណៈ ហៅភ្ញៀវមួយកងអីទៅ ចងដៃម្នាក់៥បាត១០បាតអី ចងដៃ ។

ប៉ុនថនៈ ចឹងមានចងលុយដែរ?

ណាណៈ កាលហ្នឹងមានលុយបាតបានចាយបន្តិចៗហើយ ធ្វើស្បូវអីលក់គេចងដៃទៅបានចំណងដៃ ៥០០បាត ។

ប៉ុនថនៈ ចឹងមានចាយលុយហើយ?

ណាណៈ ចាយហើយ គេចាយលុយបន្តិចៗហើយ កាលពីដំបូងបន្តស់មិនដឹងមានលុយចាយទេ ថៃចូលមកថាឲ្យយើង ធ្វើស្បូវលក់ឲ្យគេ ឲ្យយើងដុតធ្យូងលក់ឲ្យគេ ដុតធ្យូងលួច លួចកាប់ឈើមៃព្រៃគេចាប់ទៀត ។

ប៊ុនថនៈ មៃព្រៃខាងណា?

ណាណៈ មៃព្រៃខាងថៃ ។

ប៊ុនថនៈ យើងកាប់ខាងថៃ?

ណាណៈ ចាស!បើយើងនៅដីថៃ ។

ប៊ុនថនៈ ក្រោយឆ្នាំ៩០ហ្នឹង?

ណាណៈ អត់ទេ កាលនៅលើភ្នំ ពេលខ្ញុំរៀបហើយ ។

ប៊ុនថនៈ ចឹងកាលមីងនៅលើភ្នំ មីងនៅខាងខ្សែទឹកខាងថៃ?

ណាណៈ ចាស!ខ្សែទឹកខាងថៃ ។

ប៊ុនថនៈ ចឹងជំរំជាំស្វាហ្នឹងនៅខាងថៃ?

ណាណៈ នៅខាងថៃ ទឹកដីថៃទេ ។

ប៊ុនថនៈ ចឹងដល់ឆ្នាំ៩០ បានមីងចុះមកក្រោម?

ណាណៈ ចាស!មកនៅដុបរុនមកនៅក្រោម មកដីក្រោមហ្នឹងនៅជិតបន្ទាយទាហានហ្នឹង ។

ប៊ុនថនៈ ចឹងមកនៅខាងខ្មែរវិញ?

ណាណៈ ចាស!មកនៅខាងខ្មែរវិញ ។

ប៊ុនថនៈ ចឹងពីណាមកគ្រប់គ្រងនៅដុបរុនហ្នឹង?

ណាណៈ អ៊ំហឿន ។

ប៊ុនថនៈ ចឹងអ៊ំហឿន ដដែល?

ណាណៈ ចាស ។

ប៊ុនថនៈ មីងនៅដុបរុនបានរយៈពេលប៉ុន្មាន?

ណាណៈ មកនៅខាងក្រោមនេះមកនៅបានពីរឆ្នាំ បីឆ្នាំបានរត់ទៅនោះទៀត ។

ប៊ុនថនៈ នៅជុំជាមួយគ្រួសារមីង?

ណាណៈ ចាស!ខ្ញុំនៅជុំគ្នាហើយ តែរត់ទៅបែកគ្នា ប្តីខ្ញុំគេយកទៅឲ្យនៅលើភ្នំបាញ់កាំភ្លើង ។

ប៊ុនថនៈ ចឹងមីងនៅបីឆ្នាំហើយមីងរត់ទៅនៅណា?

ណាណៈ បានរត់ទៅនៅអូរជីក ។

ប៊ុនថនៈ រត់នៅនៅអូរជីក?

ណាណៈ ចាស ។

ប៊ុនថនៈ អូរជីកនៅក្នុងស្រុកអន្លង់វែង?

ណាណៈ ចាស ។

ប៊ុនថនៈ ម៉េចបានគេឲ្យមីងមក?

ណាណៈ គេថាឲ្យយើងចុះមកគេថាយើងត្រូវគ្នាហើយ មិនអីទេ ចឹងគេឲ្យយើងចុះមកនៅក្រោមគ្រប់គ្នាចឹង ដល់ពេលគេវាយម្ដងទៀតទៅនាំគ្នារត់ទៅនៅអូរជីក រត់បែកគ្នា ខ្ញុំរត់ជាមួយកូនពីរនាក់ ហើយប្ដីនៅលើភ្នំហ្នឹង នៅបាញ់កាំភ្លើងធំ ។

ប៊ុនថនៈ គាត់នៅកងវរៈលេខប៉ុន្មានមីង?

ណាណៈ គាត់នៅជាមួយអ៊ំហឿន ហ្នឹង ។

ប៊ុនថនៈ ចឹងប្ដីនៅលើភ្នំ?

ណាណៈ ចាស!រត់ទៅនោះបានមួយខែពីរនោះបានគាត់ សុំច្បាប់គេបានទៅ កាលហ្នឹងកូនខ្ញុំឈឺកូនខ្ញុំឈឺទៅស្លាប់នៅនោះ បានគេឲ្យប្ដីខ្ញុំទៅ ។

ប៊ុនថនៈ ចឹងមីងនៅអូរជីកហ្នឹងមានរបបរស់នៅអី មានគេឲបត្តូម្ភប្ដ្ឋើខ្លួនឯង?

ណាណៈ អត់ទេធ្វើខ្លួនឯងស្រូវអង្ករខ្លួនឯង តែដីគេភ្ជួរត្រាក់ទ័រឲ្យស្រេចចឹងទៅយើងយកចប់ កាប់ៗទៅដាក់ដាំទៅ ។

ប៊ុនថនៈ ទៅច្រើនគ្រួសារទេ?

ណាណៈ ច្រើនលោកគ្រួសារកងទ័ពហ្នឹងទាំងអស់ គ្រប់គ្នាធ្វើតែចឹងឯង ហើយចេះជួយគ្នា ដូចថាយើងយកដៃគ្នាមួយ ថ្ងៃចឹងទៅ ធ្វើស្រែនោះមួយថ្ងៃធ្វើស្រែនេះមួយថ្ងៃតែធ្វើបានតិចៗមួយថ្ងៃកាប់បានប្រហែលទីដុះហ្នឹងឯង ហើយក៏ដាំទៅ ។

ប៊ុនថនៈ ចឹងធ្វើឯកជនហើយឬមួយធ្វើរួម?

ណាណៈ ធ្វើឯកជនតែដល់យើងធ្វើធ្វើរួម ។

ប៊ុនថនៈ ដល់ពេលបានផលយើងយកទៅដាក់រួមឬក៏ដាក់ផ្ទះយើង?

ណាណៈ អត់ទេ ធ្វើផ្ទះយើងតើ បើយើងលក់គេបង្កើតអ្នកទិញរដ្ឋអ្នកទិញខាងតាម៉ុក ហ្នឹងបង្កើតរដ្ឋឲ្យទិញស្រូវចឹងធ្វើ បានច្រើនចឹងយើងលក់ឲ្យគាត់ខ្លះទៅ គេយកទៅកិនអង្ករឲ្យកងទ័ពខ្លះគេថាចឹង ។

ប៊ុនថនៈ ចឹងលក់យកជាលុយឬមួយយកជាស្អី?

ណាណៈ លក់យកលុយ ។

ប៊ុនថនៈ យកលុយអីវិញមីង?

ណាណៈ យកលុយខ្មែរយើងហ្នឹង ។

ប៊ុនថនៈ ចុះលុយបាតអីនោះ?

ណាណៈ លុយបាត អត់មានទេ ចុះមកនេះហើយឈប់មានលុយបាតហើយ មានតែលុយខ្មែរ ។

ប៊ុនថនៈ ចឹងមីងមានផ្ទះមានអីទេ?

ណាណៈ មានកូនផ្ទះតូចៗ ខ្ទមៗ បាំងស្លឹកបាំងអី ។

ប៊ុនថនៈ កាលហ្នឹងមីងមានកូនប៉ុន្មានហើយ?

ណាណៈ មានកូនពីរ ។

ប៊ុនថនៈ ចឹងស្លាប់ម្នាក់?

ណាណៈ ស្លាប់ម្នាក់នៅអូរជីកស្លាប់នៅនេះមួយកាលចុះឆ្នាំ៩០ ឆ្នាំ៩០ស្លាប់មួយទៅនៅអូរជីកហ្នឹង ស្លាប់មួយ ។

ប៊ុនថនៈ មីងនៅហ្នឹងរហូតឬមួយដូរទៅណាទៀត?

ណាណៈ នៅហ្នឹងហើយដល់៩៧យើងផ្ដាច់ខ្លួននេះ ខ្ញុំមកនៅនេះវិញ មកនៅទំនប់ដាច់នេះវិញ ។

ប៊ុនថនៈ ៩៨មកនៅទំនប់ដាច់វិញ?

ណាណៈ ចាស!ទំនប់ដាច់ ដល់មកនៅទំនប់ដាច់ទៅគេថាលែងអីហើយខ្ញុំមានតែបាតដៃទទេអត់មានអីទេ ដល់គេវាយមួយគ្រឹមវាយផ្ដាច់ទៅខ្ញុំចោលអស់ ប្ដីខ្ញុំមានតែខោខ្លី ខ្ញុំមានតែខោអាវជាមួយកូនស្រី កាលហ្នឹងនៅសល់កូនតែមួយ ។

ប៊ុនថនៈ បាទ ។

ណាណៈ នៅសល់កូនមួយទៅស្រាតខ្លួនទទេទៅអត់មានខោអាវទេ គេរត់ចោលអស់ ខោអាវគេយកអស់រលីង ចានឆ្នាំង គេយកអស់ ទៅក៏មកនៅសុំកន្លែងគេនៅក៏បានខាងឯកឧត្តមខាង ទាញបាញ់គាត់ចុះមកគាត់យកស្បៀង យកអីដាក់យន្តហោះចុះមកបានហ្នឹងឯង គាត់អង្គរជួយត្រីខ មី ខោអាវធំៗដាក់ច្រកស្បោងដាក់ពីលើយន្ត ហោះមកចែកប្រជាជន ។

ប៊ុនថនៈ ពេលផ្ដាច់ខ្លួនហ្នឹង?

ណាណៈ ចាស! ពេលផ្ដាច់ខ្លួនឆ្នាំ៩៨ហ្នឹង ។

ប៊ុនថនៈ ចឹងពេលមីងមកនៅភូមិនេះសព្វថ្ងៃហ្នឹង មីងមកក្នុងឆ្នាំណា?

ណាណៈ ខ្ញុំចេញពីទំនប់ដាច់ទៅនៅអូរស្វាយនោះនៅក្នុងព្រៃ ដល់ពេលនៅក្នុងព្រៃទៅដល់ពេលទៅគេកើតផ្លូវមកតាមនេះ ខ្ញុំចេញមកនៅនេះ ខ្ញុំចេញមកឆ្នាំ២០០១ ។

ប៊ុនថនៈ ឆ្នាំ២០០១?

ណាណៈ ចាស!នៅកើតភូមិកើតផ្ទះអីណឹងអស់ហើយហ្នឹង តែមិនទាន់មានផ្លូវទៅនោះ ដល់ពេលរដ្ឋាភិបាលធ្វើផ្លូវជាតិ មកខាងនេះក៏មកនៅនេះ ។

ប៊ុនថនៈ គេចែកឲ្យដីនេះ?

ណាណៈ ចាស!ដីនេះខាងភូមិឃុំគេចែក ។

ប៊ុនថនៈ មីងបានធំដែលមានបណ្តោយប៉ុន្មាន?

ណាណៈ ដីបណ្តោយ២០០ទៅក្រោយក្បាល៥០ ។

ប៊ុនថនៈ ធំដែរ?

ណាណៈ ចាស ។

ប៊ុនថនៈ ចឹងផ្ទះហ្នឹងសង់ឆ្នាំណាមីង?

ណាណៈ មីងធ្វើឆ្នាំ២០០៦ ។

ប៊ុនថនៈ ចឹងពេលមានព្រឹត្តិការណ៍សម្លាប់ សុន សេន មីងមានដឹងទេ?

ណាណៈ ដឹងតើ ។

ប៊ុនថនៈ កាលហ្នឹងមីងនៅណា?

ណាណៈ នៅអូរជីក ចល័តនៅខាងអូរជីក នៅលើភ្នំ ខាងលោកតាសុន សេន នៅលើភ្នំ ខ្ញុំនៅក្រោម កាលហ្នឹងគេ សម្លាប់តាសុន សេន សម្លាប់នៅលើភ្នំខាងច្រកសាងាំ ។

ប៊ុនថនៈ សម្លាប់នៅលើភ្នំហ្នឹង?

ណាណៈ សម្លាប់នៅលើភ្នំ ។

ប៊ុនថនៈ ចឹងមីងដឹងដែរ?

ណាណៈ ដឹងដែលតើ ។

ប៊ុនថនៈ តែពេលសម្លាប់ហ្នឹងមានជ្រួលច្របល់អីទៀតទេ?

ណាណៈ កាលហ្នឹងសម្លាប់ដូចជាមានព្រឹត្តការណ៍ដែរ កាលហ្នឹងមានបែងចែកគ្នាចង់វាយគ្នាមួយសារដែលកាលហ្នឹង ។

ប៊ុនថនៈ ចឹងមីងនៅខាងណាវិញកាលហ្នឹង?

ណាណៈ នៅដដែលអត់មានទៅណាទេ នៅតាមផ្ទះរៀងៗខ្លួនប្រពន្ធទ័ព ចឹងអឺហឿន ថាមិនឲ្យទៅណាទេ កុំឲ្យឈូឆតាមគេ នៅឲ្យស្ងៀមទៅយើងអត់មានអីទេ យើងនៅស្ងៀមទៅក៏ស្ងាត់រហូតទៅ ។

ប៊ុនថនៈ ចឹងស្ងាត់រហូតដល់ឆ្នាំ៩៨ហ្នឹង?

ណាណៈ  ចាស!ដល់ឆ្នាំ៧៨គេដកប្ដីខ្ញុំឲ្យមកនៅខាងទំនប់ដាច់
នៅទំនប់ដាច់ទៅមើលខាងមីងៗខាងជនពិការ  គេឲ្យមកនៅ
ទំនប់ដាច់ទៅក៏គេផ្ដាច់ខ្លួនឆ្នាំ៧៨ក៏រត់ទាំងអស់ចប់ទាំងអស់ហ្នឹងទៅ ។

ប៊ុនថន:  ចឹងពេលចាប់គាសារៀន មីងមានដឹងទេ?

ណាណៈ  ដឹងដែលតើ  គេចាប់យកទៅដាក់អីទេកាលហ្នឹង ។

ប៊ុនថន:  មីងមានបានទៅមើលអីទេ?

ណាណៈ  ខ្ញុំអត់មានទៅមើលទេ  ខ្លាចគេថាអត់ហ៊ានទៅមើលទេ  ខ្លាច  ប៉ុន្តែប្ដីខ្ញុំគេឲ្យមកមើលខាងប្រពន្ធកូនគាត់ឲ្យមកមើលគ្រប់គ្រងប្រពន្ធកូនគាសារៀន  ហ្នឹង ។

ប៊ុនថន:  បាទ ។

ណាណៈ  គេយកមកនៅមួយកន្លែង  គេមិនឲ្យនៅជិតគេទេ  យកមកនៅមួយកន្លែងអីទំនប់ដាច់នេះ  ពួកខ្ញុំកំណើតនៅនោះ  ដល់ចឹងទៅកើតជានៅមិនទាន់បានប៉ុន្មាន  ក៏គេផ្ដាច់ខ្លួន៧៨ហ្នឹងទៅបោលទាំងអស់ ។

ប៊ុនថន:  គេអត់មានសម្លាប់ប្រពន្ធកូនទេ?

ណាណៈ  គេអត់មានសម្លាប់ទេ  សម្លាប់តែម៉ែឪកូនប្រសារមួយប៉ុណ្ណោះឯង ។

ប៊ុនថន:  ចឹងពេលសមាហរណ៍កម្មហើយ  ពូត្រូវជាគ្រួសារមីងនៅជាកងទ័ពដដែល?

ណាណៈ  ចាស!នៅជាកងទ័ពដដែលហ្នឹង ។

ប៊ុនថន:  ចឹងឥឡូវគាត់នៅជាកងទ័ពទៀតទេ?

ណាណៈ  ឥឡូវគាត់នៅជាកងទ័ពដែលតើ  ដល់ហើយឥឡូវមេឃុំជ្រើសរើសឲ្យគាត់មកធ្វើជាមេភូមិតែមានឈ្មោះនៅ  កងទ័ពហ្នឹងឯង ។

ប៊ុនថន:  មេភូមិអីវិញ?

ណាណៈ  មេភូមិបន្ទាយចាស់ ។

ប៊ុនថន:  មេភូមិហ្នឹងតែម្ដង?

ណាណៈ  ចាស ។

ប៊ុនថន:  ចឹងសព្វថ្ងៃមីងប្រកបរបរអីដែរ?

ណាណៈ  ធ្វើស្រែចម្ការហ្នឹងលោកគ្រូ  ខ្ញុំអត់មានធ្វើអីទេ ។

ប៊ុនថន:  ពូមេភូមិ?

ណាណៈ  ចាស!  គាត់ធ្វើមេភូមិបានប្រាក់ខែបន្តិចៗ  ខ្ញុំធ្វើស្រែនិងចម្ការអត់មានរកអីទេ ។

ប៊ុនថន:  ចម្ការដំឡូង?

ណាណៈ ចាស ។

ប៊ុនថន: មានដាំសណ្ដែកទេ?

ណាណៈ អត់មានដាំសណ្ដែកទេ ដាំបន្តិចបន្តួច ខែវស្សាលក់ពោត ហើយគាស់ដំឡូវបានបន្តិចដាំដំឡូង ខែស្រូវធ្វើស្រែ ។

ប៊ុនថនៈ មីងនៅហ្នឹងមានវត្តមានអីទេ?

ណាណៈ កាលមុនអត់មានទេ កាលមុនអត់មានវត្តទេ វត្តទើបកសាងពេលពួកខ្ញុំមកនៅនេះទេ ។

ប៊ុនថនៈ ចឹងមីងមានបានទៅវត្តអីទេ ពេលសមាហរណ៍កម្មហើយអីហ្នឹង?

ណាណៈ ពេលសមាហរណ៍កម្មហើយ អត់ទាន់មានទេ ទាល់តែនៅយូរទៅបានមានអ្នកមកពីក្នុងគេយកលុយមកកសាង វត្តទៅ ពួកខ្ញុំក៏នាំគ្នាកសាងទៅ ធ្វើបុណ្យអីទៅ ។

ប៊ុនថនៈ ពីមុនមកអត់ដែលទេ?

ណាណៈ អត់ដែលទេ អត់មានវត្តមានអីផង តែនាំគ្នាធ្វើបុណ្យខែហើយស្រូវអីហ្នឹង ធ្វើបុណ្យភូមិបុណ្យដែលហ្នឹង មាន តាអាចារ្យចាស់ម្នាក់នាំគ្នាធ្វើបុណ្យទៅ ។

ប៊ុនថនៈ កាលមុន?

ណាណៈ ចាស!ធ្វើបុណ្យភូមិអីទៅ ដល់ពេលយើងហើយស្រូវប្រមូលគ្នាធ្វើបុណ្យទៅ ។

ប៊ុនថនៈ ចឹងនៅពេលមីងធ្លាប់ឆ្លងកាត់របបខ្មែរក្រហមអីចឹង មីងមានដែលនិយាយប្រាប់កូនចៅអីទេ?

ណាណៈ ចាស!មិនដែលនិយាយប្រាប់ទេ ។

ប៊ុនថនៈ យ៉ាងម៉េចបានមីងមិនដែលនិយាយប្រាប់?

ណាណៈ រាល់ថ្ងៃបុណ្យកុំឲ្យមានសង្គ្រាម ខ្លាចកើតសង្គ្រាមកុំឲ្យឆ្លងកាត់ដូចម៉ែទៀត វាពិបាកមិនឲ្យមានចឹងទេ បុណ្យមិន ឲ្យមានសង្គ្រាមកើតឡើងចឹងទៀតទេ ខ្លាចកូនៗវាពិបាកវេទនាណាស់ ។

ប៊ុនថនៈ ចឹងសព្វថ្ងៃមីងមានកូនប៉ុន្មាននាក់មីង?

ណាណៈ មានកូន៤ខ្ញុំ ។

ប៊ុនថនៈ កូនមីងរៀនដល់ណាខ្លះ?

ណាណៈ អាបងរៀនថ្នាក់ទី៨ ទី២នេះរៀនថ្នាក់ទី៤ ។

ប៊ុនថនៈ រៀននៅណាថ្នាក់ទី៨?

ណាណៈ ថ្នាក់ទី៨រៀននៅទឹកថ្លានោះ ដល់ថ្ងៃនេះប្រាប់ម៉ែថា ខ្ជិលទៅរៀនទៅជួយគាស់ដំឡូង ទៅគាស់ដំឡូងបាត់ទៅអត់ទៅរៀន ឪពុកវារអ៊ូថា កូនឯងអត់ទៅរៀនទេ កូនថាសុំមួយថ្ងៃទៅពុកអើយ ។

ប៊ុនថនៈ ចឹងមានស្រីប៉ុន្មានប្រុសប៉ុន្មាន?

ណាណេះ ស្រីពីរប្រុសពីរ តែអាបងគេទៅថៃ ។

ប៊ុនថនះ គេទៅធ្វើការអី?

ណាណេះ គេទៅធ្វើការបុះទូកអីណាទេ លោកគ្រូ គេឲ្យមកផ្ទះក៏មិនមក ។

ប៊ុនថនះ ប៉ុន្មានខែបានមកលេងផ្ទះម្តង?

ណាណេះ មិនដែលមកទេ តែទើបទៅមិនទាន់បានមួយឆ្នាំផង ចូលឆ្នាំហើយបានទៅ ទើបបានប៉ុន្មានខែហ្នឹង ។

ប៊ុនថនះ ចឹងមានទូរស័ព្ទមកលេង?

ណាណេះ ចាស!តេ មកលេងដែលតើ ។

ប៊ុនថនះ ចឹងមីងមកពីខេត្តផ្សេងចឹង មីងមករស់នៅស្រុកត្រពាំងប្រាសាទចឹង ការរាប់អានមីងជាមួយអ្នកជិតខាងហ្នឹង យ៉ាងម៉េចដែលមីង អ្នកមកពីស្រុកឆ្ងាយដូចគ្នាចឹង?

ណាណេះ រាប់អានចាត់ទុកគ្នាធម្មតា រាប់គ្នាដូចជាបងប្អូនចឹង ។

ប៊ុនថនះ មកពីឆ្ងាយដូចគ្នា?

ណាណេះ ចាស!ឆ្ងាយពីគ្នារាប់ដូចបងប្អូនចឹងណា ។

ប៊ុនថនះ មីងមានដឹងថាមកពីខេត្តណាខ្លះទេ?

ណាណេះ មានច្រើនណាស់ចំរុះគ្នា ខ្លះនៅព្រះវិហារខ្លះនៅកំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ចាម អីណាទេ ច្រើនចំរុះគ្នាទៅ ណាស់ ។

ប៊ុនថនះ មីងធ្លាប់ឆ្លងរបបមុនរហូតដល់មានសមាហរណ៍កម្មហើយ
ដល់សព្វថ្ងៃនេះបើមីងប្រៀបធៀមទៅមានភាពខុស គ្នាប៉ុណ្ណាមីង?

ណាណេះ ខុសគ្នាឆ្ងាយណាស់ រាល់ថ្ងៃនេះយើងធ្វើស្រែចម្ការយើងអត់មានខ្លាច នៅជំនាន់នោះខ្ញុំទោះបីទៅធ្វើស្រែចម្ការ ក៏នៅតែខ្លាច ថ្នក់កូនចងជាប់និងខ្លួនចឹងឯង ខ្លាចកូនមិនឲ្យដាច់ពីខ្លួនទេ ឥឡូវយើងចង់ដេកនៅណាក៏បានវា ស្រួលដែរ ។

ប៊ុនថនះ ចឹងខ្ញុំដូចជាអស់អីសួរហើយមីងមានអីចង់បន្ថែមទេ?

ណាណេះ អត់មានអីថែមទេ លោកគ្រូ ។

ប៊ុនថនះ ចឹងខ្ញុំអរគុណមីងច្រើន ។

ណាណេះ ចាស ។

**ចប់**